**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការក្រុងព្រះសីហនុ
<u>សំណុំរឿងព្រហ្មទណ្ឌ</u>
លេខ ១៦៥ ចុះថ្ងៃទី ១៩
ខែ សីហា ឆ្នាំ ២០០៤
<u>សាលក្រម</u>
លេខ ១១៣ ចុះថ្ងៃទី ១៦
ខែ ធ្នូ ឆ្នាំ ២០០៤

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការក្រុងព្រះសីហនុ**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ បានបើកសវនាការជាសាធារណៈនៅតុលាការក្រុងព្រះសីហនុ នាថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៤ ដោយមានសមាសភាពដូចតទៅ :

**<u>ចៅក្រមជំនុំជំរះ</u>**

លោក [redacted] អនុប្រធានតុលាការក្រុងព្រះសីហនុ

**<u>តំណាងអយ្យការ</u>**

លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការក្រុងព្រះសីហនុ

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោក [redacted] ជាក្រឡាបញ្ជីសវនាការ

សាលក្រមនេះចូលស្ថាពរហើយ
ក្រុងព្រះសីហនុ,ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៥
ក្រឡាបញ្ជី
[redacted]

ដើម្បីជំនុំជំរះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១៦៥ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៤ ដែលមានជនជាប់ចោទឈ្មោះ :

-ឈ្មោះ **គ សខ** ឈ្មោះហៅក្រៅ **ត** ភេទប្រុស អាយុ ២២ឆ្នាំ ជាតិខ្មែរ កើតនៅភូមិតាពីង ឃុំភ្លើលាវ ស្រុកកំពង់ត្រាច ខេត្តកំពត ទីលំនៅសព្វថ្ងៃក្រុម៣ ភូមិ៣ សង្កាត់៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ របររកស៊ីកម្មករទូកនេសាទ ឪពុកឈ្មោះ **គ ខល** (រ) ម្តាយឈ្មោះ **ស ឈ** (រ) ប្រពន្ធឈ្មោះ **ទ ល** កូនគ្មាន ទោសពីមុនមាន ធ្លាប់ជាប់ពន្ធនាគារក្រុងព្រះសីហនុម្តង ពីបទបង្ករបួសដោយចេតនា ។ ចាប់ខ្លួនថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៤ ឃុំខ្លួនថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៤ ។

-ត្រូវជាប់ចោទពីបទ<u>បង្ករបួសដោយចេតនា</u> ប្រព្រឹត្តនៅភូមិ ៣ សង្កាត់ ៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៤ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និង ឱ្យផ្តន្ទាទោសតាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ឈ្មោះ **ឃ មនរ** ភេទប្រុស អាយុ ២៣ឆ្នាំ ជាតិខ្មែរ របររកស៊ីនៅផ្ទះ ទីលំនៅសព្វថ្ងៃភូមិកែវក្រសាំង ឃុំកែប ខណ្ឌកែប ក្រុងកែប ជាជនរងគ្រោះ ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៤៧៤ ដសព.០៤ ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៤ របស់តំណាងអយ្យការអមតុលាការក្រុងព្រះសីហនុ ។

-បានឃើញដីកាបញ្ជូនរឿងទៅជំនុំជំរះលេខ ១៣១៩ ត.៣.០៤ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៤ របស់ចៅក្រមស៊ើបអង្កេតនៃតុលាការក្រុងព្រះសីហនុ ។

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជំរះលេខ ១៣២០ តព.០៤ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៤ របស់ប្រធានតុលាការក្រុងព្រះសីហនុ ។

**ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ :**

-កាលពីថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៤ ឈ្មោះ **ក** បានហៅឈ្មោះ **គ សគ** ទៅផឹកស៊ីនៅផ្ទះខ្លួន ពេលនោះក៏បានហៅ **ឃ មនះ** ទៅដែរ ។ ក្រោយពីហូបស្រាហើយ ក៏មានទំនាស់ពាក្យសំដីរវាង **គ សគ** និង **ឃ មនះ** ហើយឈ្មោះ **ឃ មនះ** បានទៅហូបបាយ ស្រាប់តែឈ្មោះ **គ សគ** បានស្ទាក់ផ្លូវចាំវាយឈ្មោះ **ឃ មនះ** ទៀត ទោះបីមានអ្នកជិតខាងឃាត់យ៉ាងណាក៏ដោយ ក៏ឈ្មោះ **គ សគ** នៅតែបង្កការវាយទៅលើឈ្មោះ **ឃ មនះ**ឲ មានរបួសយ៉ាងធ្ងន់ធ្ងរ ។

**នាពេលសវនាការ**

-ឈ្មោះ **គ សគ** ជាជនជាប់ចោទបានឆ្លើយថា ខ្លួនធ្លាប់ជាប់ពន្ធនាគារ ក្រុងព្រះសីហនុ អស់រយៈពេល ០៨ខែ កាលពីក្នុងអំឡុងឆ្នាំ ២០០៣ ។ ខ្លួនសុំបញ្ជាក់ថា នៅល្ងាចថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៤ វេលាម៉ោងប្រហែលជា ៦:០០ល្ងាច ម្ចាស់ផ្ទះគេបានមកដួលស្នាក់នៅក្បែរផ្ទះខ្លួន ហើយគេបានហៅខ្លួន និង **ឃ មនះ** ទៅហូបស្រានៅផ្ទះគាត់មានគ្នា ០៤នាក់ គឺហូបស្រាយ៉ិនស៊ីនអស់ចំនួន ០២ដប ប្រហែលជាម៉ោង ៧:០០យប់ ក៏នាំគ្នាត្រឡប់មកផ្ទះវិញ ។ ពេលដើរមកដល់ស្ពានក្រោយផ្ទះខ្លួន ឈ្មោះ **ឃ មនះ** វាបានច្រានខ្លួនពីក្រោយបណ្តាលឱ្យខ្លួនដួលផ្កាប់មុខទៅដីបណ្តាលឱ្យមុខរបួសខ្លួនរងរបួសមានឈាមហូរក្រោមភ្នែកខាងស្តាំ ហើយវាស្ទុះមកវាយខ្លួនទៀត ដោយឃើញឈ្មោះ **ឃ មនះ** វាយខ្លួនយ៉ាងដូច្នេះ ខ្លួនក៏រើសបានឈើមួយកំណាត់ ៥ x ៥ បួនជ្រុងប្រហែលកន្លះម៉ែត្រក្រវាស់ ដើម្បីការពារខ្លួនខ្លាចក្រែង **ឃ មនះ** វាយខ្លួនទៀត ក៏ឃើញត្រូវ **ឃ មនះ** ចំពីក្រោយចំកញ្ចឹងកបណ្តាលឱ្យឈ្មោះ **ឃ មនះ** ដួលផ្កាប់មុខលើស្ពាន ហើយសន្លប់ភ្លាម១តែម្តង ក្រោយពេលសមត្ថកិច្ចចាប់ ខ្លួនទើបដឹងថា ឈ្មោះនេះមានរបួសធ្ងន់ត្រង់ច្រមុះ ។

-តាមការអានចម្លើយឈ្មោះ **ឃ មនះ** ជាជនរងគ្រោះបានឆ្លើយថា នៅថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៤ វេលាម៉ោង ៤:០០ល្ងាច ខ្លួនដឹងថា ឈ្មោះ **ក** ដែលភរិយារបស់គាត់បានសំរាលកូនប្រុសម្នាក់ ខ្លួនក៏មើលក៏ឃើញឈ្មោះ **គ សគ** នៅផ្ទះ **ក** រួចទៅហើយ ហើយគេកំពុងតែផឹកស៊ី គេក៏បានហៅខ្លួនឱ្យចូលរួមផឹកជាមួយគេបានប្រហែលកន្លះម៉ោង ស្រាប់តែពូម្ចាស់ទូករបស់ខ្លួនស្រែកហៅខ្លួនឱ្យទៅហូបបាយ ខ្លួនក៏ក្រោកឡើងដើម្បីទៅហូបបាយ ស្រាប់តែឈ្មោះ **គ សគ** បានចុះពីលើផ្ទះ **ក** មុនខ្លួនទៅទៀតមិនដឹងគោលបំណងគេទៅណាឡើយ ខ្លួនដើរបានប្រហែល ០៥ម៉ែត្រ ស្រាប់តែឃើញឈ្មោះ **គ សគ** រើសដំបងឈើ ១ដើម បំរុងវាយខ្លួន តែមានគេឃាត់វាក៏ឈប់ទៅវិញ ខ្លួនក៏គៀកកវាឡើងទៅលើថ្នល់ ដើម្បីទៅហូបបាយពេលដើរមកដល់ស្ពានច្រកផ្លូវតូច ខ្លួនក៏បានដើរមុនឈ្មោះ **គ សគ** ដើរតាមក្រោយ ក៏ឈ្មោះនេះរើសដំបងឈើមួយដើមទៀតមកវាយខ្លួនពីក្រោយ តែត្រូវម្ចាស់ទូកខ្លួនឃើញគាត់ក៏ស្រែក ខ្លួនក៏ងាកមើលក៏ឃើញឈ្មោះ **គ សគ** លើកដំបងវាយមកលើខ្លួន ខ្លួនក៏យកដៃរង ខ្លួនក៏ដួលបោកទៅលើស្ពានបណ្តាលឱ្យខ្លួនសន្លប់នៅកន្លែងកើតហេតុតែម្តង ។ ក្នុងរឿងនេះខ្លួនសុំទាមទារសំណង ២.០០០.០០០៛០០ បើឈ្មោះនេះមានលុយសង ខ្លួនសុំឱ្យតុលាការជួយបន្ធូរបន្ថយទោសឱ្យគាត់ផង ។ បើគ្មានសងទេ សុំឱ្យតុលាការផ្តន្ទាទោសតាម ច្បាប់ ។

-ឈ្មោះ **ស សះ** ជានគរបាលយុត្តិធម៌ បានឆ្លើយថា នៅថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៤ វេលាម៉ោង ១៧ និង ៣០នាទី នៅចំណុចក្រុម ៣២ ភូមិ ៣ សង្កាត់ ៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ នៅផ្ទះ **ក** មានការឈ្មោះ

គ្នារវាងឈ្មោះ គ **សត** ជាមួយឈ្មោះ **យ មនះ** ដោយសារមានទំនាស់គ្នានៅពាក្យសំដី គឺខ្លួនបានទទួលពាក្យបណ្តឹងពីជនរងគ្រោះ ដោយមានម្ចាស់ទូកបាននាំជនរងគ្រោះមកប្តឹងនៅការិយាល័យព្រហ្មទណ្ឌកើតធ្ងន់តែម្តង ខ្លួនក៏បានចាត់ការតាមនីតិវិធីតទៅរួចហើយ ក៏បញ្ជូនជនល្មើស និង វត្ថុតាងព្រមទាំងសំណុំរឿងមកតុលាការ ដើម្បីចាត់ការតាមច្បាប់តទៅទៀត ។ ឯរឿងរ៉ាវអ្វីផ្សេងទៀត ខ្លួនមិនបានដឹងឡើយ ។

-បានឃើញកំណត់ហេតុទទួលវត្ថុតាងរបស់តំណាងអយ្យការចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៤ ដែលទទួលវត្ថុតាងពីនគរបាលក្រុងនូវឈើបួនជ្រុងទំហំ ០,០៥ x ០,០៥ ប្រវែង ០,៦០ម ចំនួន ០១ ដើម ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ គ **សត** ពីបទបង្ករបួសដោយចេតនា ប្រព្រឹត្តនៅសង្កាត់ ៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៤ ប៉ុន្តែឈ្មោះនេះកន្លងមកធ្លាប់ជាប់ពន្ធនាគារម្តងរួចមកហើយ ក្នុងអំឡុងឆ្នាំ ២០០៣ កន្លងផុតទៅនេះ តែក្នុងអំឡុងឆ្នាំ ២០០៤ នេះទៀតសោតឈ្មោះនេះបានប្រព្រឹត្តបទល្មើសម្តងទៀត ឃើញថា មិនរាងចាលសោះ ហេតុនេះសុំឱ្យលោកចៅក្រមមេត្តាសំរេចដាក់ទណ្ឌកម្មជនល្មើសអោយបានធ្ងន់ធ្ងរបន្តិច ទៅតាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ដោយអនុគ្រោះ ។

-ឈ្មោះ គ **សត** បានឆ្លើយសំដីចុងក្រោយបង្អស់ថា ខ្លួនសុំឱ្យតុលាការជួយបន្ធូរបន្ថយទោសឱ្យខ្លួនផង ខ្លួននិង សុខចិត្តលត់ដំកែប្រែខ្លួនឱ្យក្លាយទៅជាពលរដ្ឋដ៏ល្អនៅក្នុងសង្គម ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់ការអានចម្លើយជនរងគ្រោះ

-ក្រោយពីបានស្តាប់ចម្លើយសាក្សី

-ក្រោយពីបានពិនិត្យភស្តុតាង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សំដីចុងក្រោយបង្អស់របស់ជនជាប់ចោទ

## តុលាការក្រុងព្រះសីហនុ

-ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## យល់ឃើញថា

នៅថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៤ វេលាម៉ោង ០៤ ទៅ ០៥ល្ងាច មានករណីបង្ករបួសដោយឈ្មោះ គ **សត** បានយកឈើបួនជ្រុងវាយទៅលើឈ្មោះ **យ មនះ** តែជនរងគ្រោះយកដៃរង បណ្តាលឱ្យដួលបោកទៅលើស្ពានត្រូវច្រមុះចេញឈាមហើយសន្លប់ ។ តែក្នុងពេលសវនាការនេះជនជាប់ចោទបានឆ្លើយថា ខ្លួនគេមិនបានវាយទេ គឺគ្រវាស់ឈើការពារខ្លួន ខ្លាចក្រែងឈ្មោះ **យ មនះ** វាយខ្លួនទៀត ចម្លើយនេះជនជាប់ចោទឆ្លើយដើម្បីការពារខ្លួនតែប៉ុណ្ណោះតាមពិតជនជាប់ចោទមិនមែនគ្រវាស់ឈើទេ គឺវាយតែម្តង វាយពីក្រោយនៅពេលជនរងគ្រោះ មិនដឹងខ្លួនតែត្រូវបានសាក្សីគេស្រែកទាន់ កុំអីឈ្មោះ **យ មនះ** មិនដឹងត្រូវចំកន្លែងណាទៀតទេ ។

-តាមចម្លើយជនរងគ្រោះបានបញ្ជាក់ថា នៅពេលដែលម្ចាស់ទូកហៅខ្លួនឱ្យទៅហូបបាយ ខ្លួនក៏ត្រៀមចុះទៅតែខ្លួនគាត់ឃើញឈ្មោះ គ **សត** បានចុះពីកន្លែងផឹកស៊ីមុនគាត់ទៅទៀត តាមពិតឈ្មោះនេះបានចុះទៅត្រៀម ដើម្បីវាយជនរងគ្រោះតែម្តង ព្រោះតាមចម្លើយសាក្សីបញ្ជាក់ថា នៅពេលផឹកស៊ី គឺមានការទាស់ពាក្យសំដីនឹងគ្នារវាង

គ សគ និង ឃ មនះ ដោយសារមានការទាស់សំដីយ៉ាងដូច្នេះ ទើបឈ្មោះ គ សគ មានគោលបំណងវាយឈ្មោះ ឃ មនះ ឱ្យខាងតែបាន គឺបានចុះពីលើផ្ទះមុន ឃ មនះ ទៅទៀត ។

-ចម្លើយសាក្សី និង ភស្តុតាងមានមូលដ្ឋានគ្រប់គ្រាន់គួរឱ្យតុលាការយកជាការបាន ។

-បណ្តឹងទាមទារសំណងថ្លៃថ្នាំព្យាបាលរបួស និង ជម្ងឺចិត្តមានលក្ខណៈសមស្រប គប្បីតុលាការពិនិត្យពិចារណាដល់បញ្ហានេះ ។

-មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ គ សគ ពីបទបង្ករបួសដោយចេតនា ប្រព្រឹត្តនៅសង្កាត់ ៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ឱ្យផ្តន្ទាទោសតាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

## ហេតុដូច្នេះតុលាការខេត្តព្រះសីហនុ

## សំរេច :

**ផ្តន្ទាទោស :**

១-ឈ្មោះ គ សគ ភេទប្រុស អាយុ ២២ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន ០១ ឆ្នាំ ០៥ ខែ ( មួយឆ្នាំប្រាំខែ ) គិតពីថ្ងៃចាប់ខ្លួន ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៤ ពីបទបង្ករបួសដោយចេតនា ប្រព្រឹត្តនៅភូមិ ៣ សង្កាត់ ៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៤ ពីបទបង្ករបួសដោយចេតនា ប្រព្រឹត្តនៅភូមិ ៣ សង្កាត់ ៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ឱ្យផ្តន្ទាទោសតាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២-ឱ្យឈ្មោះ គ សគ សងសំណងថ្លៃថ្នាំព្យាបាលរបួស និង ជម្ងឺចិត្តជាទឹកប្រាក់ចំនួន ១.០០០.០០០រ៉ុ០០ ( មួយលានរៀល ) ទៅឈ្មោះ ឃ មនះ ជាជនរងគ្រោះ ចាប់តាំងពីសាលក្រមនេះចូលជាស្ថាពរ ។ សំណើលើសពីនេះបដិសេធចោល ។

ក្នុងករណីទណ្ឌិតគ្មានប្រាក់ធនទណ្ឌទេ ត្រូវដាក់គុកបង្ខំដល់រូបកាយតាមមាត្រា ៧ នៃច្បាប់ស្តីពីការដាក់គុកបង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌ ។

សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈនៅចំពោះមុខជនជាប់ចោទ កំបាំងមុខជនរងគ្រោះ បើកផ្លូវប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍ក្នុងកំឡុងច្បាប់ ។

**ក្រឡាបញ្ជី** [redacted]

**ចៅក្រមជំនុំជម្រះ** [redacted]